ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រ

# របស់

# សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ឧសភា ២០០៩ ~ ឧសភា ២០១៤

បានទទួលការឯកភាពពីក្រុមការងារជាន់ខ្ពស់តុលាការគំរូនាថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០០៩

## ១. ប្រវត្តិសង្ខេបរបស់តុលាការ

### សេចក្តីផ្តើម

តុលាការកម្ពុជា ត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ១២៨ថ្មី ដែលចែងថា អំណាចតុលាការជាអំណាចឯករាជ្យ ដែលគ្រប់ដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តី រដ្ឋបាលផង ។ រដ្ឋធម្មនុញ្ញក៏ចែងផងដែរថា មានតែអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

តុលាការនៃព្រះរាជាណាចក្រកម្ពុជា ចែកចេញជា សាលាដំបូង និងតុលាការជាន់ខ្ពស់ ។ សាលាដំបូងមានសាលាដំបូងខេត្ត សាលាដំបូងរាជធានី និងតុលាការយោធា ហើយតុលាការជាន់ខ្ពស់មាន សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ យោងតាមច្បាប់ សាលាដំបូងត្រូវមានអយ្យការនៅអមជាមួយ ។

សាលាដំបូងរាជធានីភ្នំពេញត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៨០ ។ អយ្យការអមសាលាដំបូង រាជធានីភ្នំពេញក៏ត្រូវបានបង្កើតឡើងនៅពេលដំណាលគ្នានោះដែរ ។

សាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មានទីតាំងស្ថិតនៅក្នុងរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចំនួនពលរដ្ឋកម្ពុជា និងជនបរទេសនៅច្រើនជាងបណ្តាខេត្តនានា ហើយជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច វប្បធម៌ ហើយជាសាលាដំបូងតែ ១ គត់ដែលមានសំណុំរឿង ច្រើនជាង គេបំផុត ។ សាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញនេះ ត្រូវតែប្រព្រឹត្តទៅដោយរលូន ប្រកបដោយប្រសិទ្ធភាព មានយុត្តិធម៌ ធានាភាពសុខសាន្ត និងការអភិវឌ្ឍន៍ ដើម្បីលើកកំពស់កិត្តិយសរបស់ព្រះរាជាណាចក្រកម្ពុជា ។

សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បាននឹងកំពុងរួមចំណែកអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ តាមរយៈកំណែទម្រង់ច្បាប់ និងតុលាការ (អាទិភាព ៥.៣.២) ដោយការរៀបចំផែនការយុទ្ធសាស្រ្ត ដើម្បីគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍ ស្របតាមទិសដៅចំបងទាំង ១០នៃតុលាការគំរូ ដូចខាងក្រោម :

ទិសដៅទី ១: តុលាការ ត្រូវតែជាកន្លែងដែលប្រជាពលរដ្ឋអាចប្រើប្រាស់បាន

ទិសដៅទី ២: តុលាការ មានដំណើរការប្រកបដោយតម្លាភាព

ទិសដៅទី ៣: ចៅក្រមសម្រេចសេចក្តី ដោយឯករាជ្យ

ទិសដៅទី ៤: ចៅក្រម ព្រះរាជអាជ្ញា មេធាវី និងមន្ត្រីតុលាការ ត្រូវមានជំនាញវិជ្ជាជីវៈ និង មានការយល់ ដឹងគ្រប់គ្រាន់

ទិសដៅទី ៥: ចៅក្រម ព្រះរាជអាជ្ញា មេធាវី និងមន្ត្រីតុលាការ បម្រើការងារ ដោយគោរពក្រមសីលធម៌

ទិសដៅទី ៦: ការស៊ើបអង្កេត និងដំណើរការតុលាការ ត្រូវបានធ្វើឡើងដោយមិនលំអៀង យុត្តិធម៌ និង ប្រកប ដោយវិជ្ជាជីវៈ

ទិសដៅទី ៧: ភាគីទាំងសងខាង ជនរងគ្រោះ និងសាក្សី ត្រូវបានគេយកចិត្តទុកដាក់ ដោយ មេត្តាធម៌ និងគោរព

ទិសដៅទី ៨: គូវិវាទមានតំណាងដែលមានប្រសិទ្ធភាព

ទិសដៅទី ៩: តុលាការមានដំណើរការប្រកបដោយសមត្ថភាព និងប្រសិទ្ធិភាព

ទិសដៅទី ១០: សាលក្រមតុលាការត្រូវបានអនុវត្ត ទៅតាមលំដាប់លំដោយ

## ទំនាក់ទំនងរវាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង ផែនការយុទ្ធសាស្ត្រតុលាការគំរូ



# រចនាសម្ព័ន្ធសាលាដំបូង និងអយ្យការអមសាលាដំបូង

**ផ្នែកតុលាការរួមមាន :**

- ប្រធាន
- អនុប្រធាន ( មួយ ឬច្រើន)
- ចៅក្រម
- នាយកក្រឡាបញ្ជី
- ក្រឡាបញ្ជី
- បុគ្គលិកផ្សេងៗទៀត

**ផ្នែកអយ្យការ :**

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- នាយកក្រឡាបញ្ជី
- ក្រឡាបញ្ជី
- បុគ្គលិកផ្សេងៗទៀត

**ផ្នែករដ្ឋបាល**

- រដ្ឋបាល
- គណនេយ្យ
- វត្ថុតាង
- ទទួលពាក្យបណ្ដឹង
- តំកល់ឯកសារ
- ពន្ធ
- គ្រប់គ្រង និងផ្គត់ផ្គង់សម្ភារៈ
- ព័តិមាន

# សំណើរចនាសម្ពន្ធ័តុលាការគំរូកម្ពុជា_តុលាការជាន់ទាប



## ឧបករណ៍សម្ភារៈ និងការិយាល័យធ្វើការ

- អាគារ
- ឃ្លាំង
- សាលសវនាការ និងព្រមទាំងសម្ភារៈផ្សេងៗ ( បញ្ជីសារពើភ័ណ្ឌតុលាការ)
- មន្ទីរស៊ើបសួរ

ដើម្បីឱ្យតុលាការដំណើរការបានពេញលេញ ត្រូវមានឧបករណ៍សម្ភារៈដូចខាងក្រោម : បន្ទប់ពិភាក្សា និង បន្ទប់សាក្សី សាលសវនាការគ្មានសំលេងរំខានក្នុងបន្ទប់ ដែលជនអសមត្ថភាពក៏អាចប្រើប្រាស់បាន មាន កន្លែងទទួលភ្ញៀវ បន្ទប់ឃុំឃាំងពីរដោយមានបង្គន់អនាម័យផង បង្គន់អនាម័យសាធារណៈ ដោយចែក ដាច់ពីគ្នារវាងបុរស និងស្ត្រី បន្ទប់ដាក់ឯកសារ បន្ទប់រក្សាវត្ថុតាងដែលមានសុវត្ថិភាព និងមាន ខ្យល់ចេញ ចូល ច្រកចេញចូលដែលមានសុវត្ថិភាពសម្រាប់ចៅក្រមនៅក្នុងសាលសវនាការ បង្គន់អនាម័យសម្រាប់ បុគ្គលិកតុលាការ កន្លែងចុះបញ្ជីធំទូលាយ បន្ទប់ប្រជុំ ឬ បន្ទប់សម្រុះសម្រួល បណ្ណាល័យ ឧបករណ៍ ទំនាក់ទំនង និងក្តាខៀនបិទប្រកាសសាធារណៈ ។

សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញនឹងសាងសង់អគារថ្មីនៅលើទីតាំង បច្ចុប្បន្ន ។ ក្នុងដំណាក់កាលនេះសាលាដំបូងត្រូវប្តូរទីតាំងទៅកាន់តុលាការកំពូលបច្ចុប្បនបណ្តោះអាសន្ន ហើយ ដែលត្រូវរំពឹងថា នឹងកើតឡើងនាចុងឆ្នាំ ២០០៩ ។

## នីតិកម្ម

ការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ និងអយ្យការ គឺផ្អែកលើរដ្ឋធម្មនុញ្ញ ព្រមទាំងច្បាប់ និង លិខិតបទដ្ឋានផ្សេងទៀត ។

## ផ្នែកដែលពាក់ព័ន្ធផ្សេងៗក្នុងរដ្ឋាភិបាល

- ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- ក្រសួងយុត្តិធម៌
- ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- សាលាដំបូងខេត្ត និង តុលាការជាន់ខ្ពស់
- នគរបាលយុត្តិធម៌( នគរបាល.កងរាជអាវុធហត្ថនិងអង្គភាពនានាដែលពាក់ពន្ធ័និងការងារ យុត្តិធម៌)

- ជំនាញកោសល្យវិច័យ/បកប្រែ

- ពន្ធនាគារ

-មន្ទីរហិរញ្ញវត្ថុ និង និងមន្ទីជុំវិញរាជធានីភ្នំពេញ

-រតនាគាររាជធានីភ្នំពេញ

- សាលារាជធានីភ្នំពេញ

- ក្រសួងសុខាភិបាល

-ក្រសួងបរិស្ថាន

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ក្រសួងមហាផ្ទៃ

-ក្រសួងការបរទេស

-ក្រសួង និងមន្ទីរពាក់ព័ន្ធផ្សេងៗទៀត

## <u>អ្នកផ្តល់សេវាសំខាន់ៗក្រៅរដ្ឋាភិបាល</u>

អ្នកផ្តល់សេវាសំខាន់ៗ រួមមានគណៈមេធាវី អង្គការជំនួយផ្នែកច្បាប់ អង្គភាពកោសល្យវិច្ច័យ និង អង្គការផ្សេងៗទៀត ដែលបំរើសេវាកម្មផ្នែកច្បាប់ ។

## <u>ហិរញ្ញវត្ថុ</u>

ហិរញ្ញវត្ថុត្រូវបានផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈក្រសួងយុត្តិធម៌ ដែលជាអាណាប័ក ដើមខ្សែគឺជាអ្នកដាក់សំណើថវិកាទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ថវិកាត្រូវបានគ្រប់គ្រង តាមរយៈ រតនាគាររាជធានីភ្នំពេញ ។

## ២. ការវិភាគបរិយាកាស

## <u>អាទិភាពសម្រាប់ការអភិវឌ្ឍន៍</u>

សាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវអនុវត្តតាមនីតិវិធីច្បាប់ដែលមានស្រាប់ និង ច្បាប់ថ្មីៗ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យមានការជឿទុកចិត្តពីប្រជាពលរដ្ឋ ។

## <u>ព្យាករណ៍បរិយាកាសសម្រាប់ឆ្នាំឆ្នាំខាងមុខ</u>

ស្របតាម គោលនយោបាយរបស់រាជរដ្ឋាភិបាល សាលាដំបូងនិងអយ្យការអមសាលាដំបូង រាជធានីភ្នំពេញអាចព្យាករណ៍បរិយាកាស សម្រាប់ប្រាំឆ្នាំ ខាងមុខឃើញថា សេដ្ឋកិច្ចមានការរីកចំរើន ការផលិត និងសេវាកម្មក៏មានការកើនឡើង រួមជាមួយនឹងកំណើនប្រជាពលរដ្ឋ ក៏មានការកើនឡើង ជា លំដាប់ ស្របនិងការអភិវឌ្ឍន៍នូវធនធានមនុស្ស ដ៏សំបូរបែប ដែលជាកត្តាមួយ ធ្វើអោយ វិវាទផ្សេង អាចកើន ឡើងច្រើនជាលំដាប់ ហើយភាគរយនៃយុវជនក្មេងៗចូលតុលាការក៏កើនឡើងដែរ ។

ការកើនឡើងនូវការវិនិយោគបរទេស និងការគ្រប់គ្រងជនបរទេសក៏ត្រូវបានរំពឹងថាអាចនឹង នាំឱ្យមានការកើនឡើងនូវវិវាទផ្សេងៗ ។ អត្រានៃអ្នកចេះអក្សរ និងយល់ដឹងអំពីច្បាប់កម្ពុជាត្រូវបាន ព្យាករណ៍ថានឹងមានការកើនឡើងផងដែរក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ដែលជាហេតុធ្វើឱ្យមានការកើន ឡើងនូវបញ្ហា ត្រូវចូលតុលាការ ហើយក៏ទាមទារនូវការផ្តល់សេវាពីសំណាក់តុលាការ និងអយ្យការឱ្យ កាន់តែប្រសើរឡើង ។

ការកើនឡើងនៃចំនួនមេធាវី ទាមទារនូវការធ្វើឱ្យប្រសើរឡើងនៃកិរិតនៃការតំណាងនៅតុលាការ ទោះបីជាសេវាទាំងនេះត្រូវបានព្យាករណ៍ នឹងកើនឡើងភាគច្រើននៅទីក្រុងធំៗក៏ដោយសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ ។

កត្តាទាំងអស់នេះ រួមទាំងច្បាប់ថ្មីៗដែលចេះតែកើនឡើងជាលំដាប់ នឹងនាំឱ្យមានការកើនឡើងនូវទំហំនិងបន្ទុកកាន់តែធ្ងន់ធ្ងរថែមទៀមសម្រាប់តុលាការ និងអយ្យការ។

## ៣. ផែនការ

### ចក្ខុវិស័យ

តុលាការមួយឯករាជ្យ និងមានដំណើរការល្អប្រសើរ ទទួលបានការជឿទុកចិត្តពីប្រជាពលរដ្ឋ។

### បេសកកម្ម

ផ្តល់យុត្តិធម៌ ក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ដោយគោរព និង អនុវត្តតាមស្តង់ដា និង លក្ខណៈវិនិច្ឆ័យជាតិ និងអន្តរជាតិ ។

### តំរិយាបថរំពឹងទុក

ដោយអនុលោមទៅតាមក្រមសីលធម៌ចៅក្រម នៅពេលបំពេញកិច្ចការតុលាការ ឬអយ្យការ

**ចៅក្រមត្រូវមានៈ**

- **វិរិយសម្បយុត្ត** = ការបំពេញកិច្ចការប្រកបដោយវិរិយភាព
- **សុចរិតយុត្តិធម៌** = ភាពទៀងត្រង់ និងយុត្តិធម៌
- **បញ្ញត្តិគារវោ** = ការប្រតិបត្តិច្បាប់ឱ្យបានម៉ឺងម៉ាត់
- **សមទណ្ឌោ** = សមភាពនៃទណ្ឌកម្មទៅលើជនដែលប្រព្រឹត្តអំពើល្មើសដូចគ្នា
- **បញ្ញាវុធវិនិច្ឆ័យ** = ការសម្រេចសេចក្ដីដែលប្រកបដោយបញ្ញា និងភាពឆ្លាតវៃ

**ត្រូវជៀសវាងនូវអគតិទាំង ៤ គឺៈ**

- **ឆន្ទាគតិ** = លំអៀងព្រោះស្រលាញ់
- **ទោសាគតិ** = លំអៀងព្រោះទោសៈ ឬស្អប់
- **ភយាគតិ** = លំអៀងព្រោះភ័យខ្លាច
- **មោហាគតិ** = លំអៀងព្រោះមោហៈ ល្ងង់ អវិជ្ជា

## រចនាសម្ព័ន្ធផែនការ

ដើម្បីបានសំរេចបេសកកម្មនេះ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានកំណត់ទិសដៅចំនួនបីដូចខាងក្រោម :

១-ការគ្រប់គ្រងរឿងក្ដីព្រហ្មទណ្ឌ រដ្ឋប្បវេណី ការងារ និងសង្គម រដ្ឋបាល និងពាណិជ្ជកម្ម ឱ្យ មាន ប្រសិទ្ធភាព

២-រដ្ឋបាលតុលាការ និងអយ្យការទទួលបានការគាំទ្រប្រកបដោយប្រសិទ្ធភាព

៣-ការគ្រប់គ្រងតុលាការនិងអយ្យការឱ្យមានប្រសិទ្ធភាព

## ទិសដៅទី ១: ការគ្រប់គ្រងរឿងក្ដីព្រហ្មទណ្ឌ រដ្ឋប្បវេណី ការងារ និងសង្គម រដ្ឋបាល និង ពាណិជ្ជកម្មឱ្យមានប្រសិទ្ធភាព

**គោលបំណងទី១.១: ការទទួល និងចុះបញ្ជីរឿងក្ដី និងការផ្ដល់ព័ត៌មាន**

**យុទ្ធសាស្ត្រ:**

១.១.១ ការពិនិត្យបណ្តឹងទាមទារ បណ្តឹងបរិហារដោយពិនិត្យលើលក្ខខណ្ឌដែលច្បាប់តំរូវ និងសមត្ថកិច្ច

១.១.២ ធ្វើបញ្ជីការ ចុះបញ្ជីនៃពាក្យបណ្តឹងទាមទារ និងបណ្តឹងបរិហារដោយដៃ និងដោយប្រពន្ធ័អេឡិចត្រូនិច ដោយធ្វើការផ្ទៀងផ្ទាត់ជាប្រចាំ ។

១.១.៣ ធ្វើការបណ្តុះបណ្តាលមន្ត្រីចុះបញ្ជីដោយដៃ និងដោយប្រព័ន្ធអេឡិកត្រូនិច ។

១.១.៤ បង្កើតបរិយាកាសនិងបង្កលក្ខណៈងាយស្រួលក្នុងការទទួលពាក្យបណ្តឹង និងការផ្តល់ព័ត៌មាន ។

## គោលបំណងទី១.២: ការបែងចែករឿងក្តីតាមនីតិវិធី

**យុទ្ធសាស្ត្រ :**

១.២.១ បង្កើតកម្មវិធីបែងចែករឿងក្តីព្រហ្មទណ្ឌ និង និងបែងចែកតាមប្រភេទនៃបណ្តឹង តាមលំដាប់ និងលំដាប់ជំនួសប្រចាំឆ្នាំ តាមក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី ។

១.២.២ រៀបចំប្រក្រតិទិនប្រចាំការ ដើម្បីទទួលសំណុំរឿងព្រហ្មទណ្ឌក្នុងសម្រាប់ថ្ងៃបុណ្យ និងថ្ងៃឈប់ សំរាកឱ្យបានល្អ ។

## គោលបំណងទី១.៣: ការរៀបចំរឿងក្តី និងការចាប់ផ្តើមនីតិវិធីឱ្យបានសមស្រប

**យុទ្ធសាស្ត្រ :**

១.៣.១ ធានាឱ្យមានការចូលរួមដល់សកម្មភាពបណ្តឹង ពីជនដែលពាក់ពន្ធ័ ដូចជា អ្នកជំនាញ មេធាវី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់សង្ស័យ... ។

១.៣.២ ធ្វើឱ្យមានប្រសិទ្ធភាពនូវការបញ្ជូនដីកា និងលិខិតផ្សេងៗដែលអាចធានាថា ជនពាក់ពន្ធក្នុងរឿងក្តី បានទទួលព័ត៌មាន ឬបានចូលខ្លួនមកតុលាការទាន់ពេល ។

១.៣.៣ ជំរុញឱ្យមានថវិការសំរាប់ដំណើការរឿងក្តីនិងទំនាក់ទំនងដើម្បីធានាប្រសិទ្ធិភាពនៃការស៊ើបសួរ និងរុករកវត្ថុតាង ។

១.៣.៤ ធានាឱ្យមានការគោរពនីតិវិធីត្រឹមត្រូវ និងឆាប់រហ័ស ។

## គោលបំណទី១.៤: សវនាការ និងការចេញសេចក្តីសំរេចតាមនីតិវិធីត្រូវ

**យុទ្ធសាស្ត្រ :**

១.៤.១ រៀបចំ និងផ្តល់ព័ត៌មានពីប្រតិទិនតុលាការ ដើម្បីកំណត់កម្មវិធីជំនុំជំរះឱ្យមានប្រសិទ្ធភាព។

១.៤.២ ធានាឱ្យមានកន្លែងគ្រប់គ្រាន់ សំរាប់ដំណើការជំនុំជំរះឱ្យបានសមស្របតាមតម្រូវការ និងមានប្រសិទ្ធិភាព។

១.៤.៣ ផ្តល់ការយកចិត្តទុកដាក់ជាពិសេស ដល់សាក្សី ជនរងគ្រោះ និងជនជាប់ចោទជាអនីតិជន ។

១.៤.៤ ធានាឱ្យមានការគោរពនីតិវិធីឱ្យបានត្រឹមត្រូវក្នុងការចេញសាលក្រម។

## គោលបំណងទី១.៥: ការជូនដំណឹងពីសេចក្តីសំរេច និងបណ្តឹងឧបាស្រ័យ ឱ្យមានប្រសិទ្ធភាព

**យុទ្ធសាស្ត្រ :**

១.៥.១ ធានាឱ្យមានការជូនដំណឹង ពីសេចក្តីសំរេចរបស់តុលាការ និងអយ្យការអមសាលាដំបូងក្រុង ភ្នំពេញឱ្យបានដល់គូភាគី និងជនពាក់ពន្ធ័តាមនីតិវិធី ។

១.៥.២ បង្កើតយន្តការត្រួតពិនិត្យតាមដាន ដើម្បីធានាដំណើរការបណ្តឹងឧបាស្រ័យស្របតាមតម្រូវការ ច្បាប់។

១.៥.៣ បង្កលក្ខណៈងាយស្រួលក្នុងដំណើរការធ្វើ ទទួល និងបញ្ជូនបណ្តឹងឧបាស្រ័យឱ្យបានឆាប់រហ័ស។

## គោលបំណងទី១.៦ : ការអនុវត្តសេចក្តីសំរេច និងការបិទបញ្ជីរឿងក្តីស្របតាមនីតិវិធីតម្រូវ

**យុទ្ធសាស្ត្រ :**

១.៦.១ ធានាឱ្យមានការអនុវត្តសាលក្រម និងដីកា ឬសេចក្តីសំរេចចិត្តឱ្យមានប្រសិទ្ធភាព និងត្រឹមត្រូវ តាមនីតិវិធី ។

១.៦.២ ធានាឱ្យមានការបិទសំណុំរឿងក្តីឱ្យបានត្រឹមត្រូវតាមនីតិវិធី ។

## ***សូចនាករតាមដានការអនុវត្តន៍សម្រាប់ទិសដៅទី១***

**ផ្នែកព្រហ្មទណ្ឌ:**

១. ប្រព័ន្ធចុះបញ្ជីរឿងក្តីព្រហ្មទណ្ឌថ្មីត្រូវបានបង្កើត និងរក្សា

២. ឧបករណ៍សម្ភារៈ និងនីតិវិធីសម្រាប់អនីតិជនត្រូវបានបង្កើតឡើងនៅតុលាការ

៣. សំណុំរឿងត្រូវបែងចែកទៅតាមប្រព័ន្ធលំដាប់ និងប្រតិទិនប្រចាំឆ្នាំរបស់តុលាការ

៤. ភាគរយនៃចំនួនរឿងក្តីដែលមានតំណាងត្រឹមត្រូវ ( ត្រូវមានចាំបាច់)

៥. ចំនួនសវនាការដែលបានធ្វើឡើង

៦. ភាគរយនៃចំនួនសំណុំរឿងដែលបានបិទ

៧. រាល់សាលក្រមរបស់តុលាការ និងរបាយការណ៍សង្ខេបត្រូវបានបញ្ជូនទៅក្រសួងយុត្តិធម៌

៨. ទណ្ឌិត និងជនជាប់ចោទត្រូវបានដោះលែងតាមពេលវេលាកំណត់

**ផ្នែករដ្ឋប្បវេណី:**

៩. ប្រព័ន្ធចុះបញ្ជីរឿងក្តីរដ្ឋប្បវេណីថ្មីត្រូវបានបង្កើត និងរក្សា

១០. ប្រព័ន្ធនៃការពិនិត្យរឿងក្តីរដ្ឋប្បវេណីត្រូវបានបង្កើត និងរក្សា

១១. សំណុំរឿងរដ្ឋប្បវេណីត្រូវបានបែងចែកទៅតាមប្រតិទិនប្រចាំឆ្នាំរបស់តុលាការ

១២. ភាគរយនៃការខកខានមិនបានចូលខ្លួនមកកាន់តុលាការនៃភាគី សាក្សី និងអ្នកជំនាញ បន្ទាប់ពី បានទទួលការជូនដំណឹង

១៣. ចំនួនសវនាការ

១៤. រាល់សាលក្រមរបស់តុលាការ និងរបាយការណ៍សង្ខេបត្រូវបានបញ្ជូនទៅកាន់ក្រសួងយុត្តិធម៌

១៥. ភាគរយនៃសំណុំរឿងដែលបានបិទបន្ទាប់ពីការអនុវត្តន៍សាលក្រមរួម

## <u>ទិសដៅទី ២: រដ្ឋបាលតុលាការនិងអយ្យការទទួលបានការគាំទ្រប្រកបដោយប្រសិទ្ធភាព</u>

### គោលបំណងទី២.១: ការរៀបចំថវិការឱ្យបានគ្រប់គ្រាន់ឱ្យសមស្របតាមតំរូវការនៃដំណើរការរបស់តុលាការ និងអយ្យការ

**យុទ្ធសាស្ត្រ:**

២.១.១ ធានាក្នុងការធ្វើផែនការប្រចាំឆ្នាំរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ ឱ្យស្របតាមតម្រូវការចំបាច់ ឱ្យបានទាន់ពេលវេលា និងស្របតាមនីតិវិធីរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២.១.២ ពិនិត្យ និងកែតម្រូវឡើងវិញនូវផែនការយុទ្ធសាស្ត្រតាមតំរូវការចាំបាច់ ។

២.១.៣ កំណត់ការចំណាយលើទំហំសេវាការងារដែលកើនឡើងសម្រាប់អគារតុលាការ និងអយ្យការថ្មី ។

**គោលបំណងទី២.២ : មធ្យោបាយនិងសម្ភារៈបរិក្ខាគ្រប់គ្រាន់សម្រាប់ដំណើរការកិច្ចការតុលាការ និងអយ្យការ**

**យុទ្ធសាស្ត្រ:**

២.២.១ សាងសង់អាគារតុលាការ និងអយ្យការថ្មី

២.២.២ រៀបចំផែនការថវិកាសំរាប់ការចំណាយលើការផ្លាស់ប្តូរទីតាំងតុលាការ និងអយ្យការ

២.២.៣ ធានាក្នុងការធ្វើផែនការថែរក្សា និងផែនការបំពេញបន្ថែមតាមតម្រូវការជាក់ស្តែង

២.២.៤ ធានានិងបង្កលក្ខណៈងាយស្រួលដល់ជនពិការ គថ្លង់ និងជនបាត់បង់សមត្ថភាព

២.២.៥ ធានាឱ្យមានឧបករណ៍ និងសម្ភារៈបរិក្ខារសម្រាប់បំរើការទូទៅរបស់តុលាការ និងអយ្យការ

**គោលបំណងទី២.៣ : ធនធានមនុស្ស និងការកសាងសមត្ថភាព**

**យុទ្ធសាស្ត្រ:**

២.៣.១ បង្កើនចំនួនចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងបុគ្គលិកជំនាញតាមទំហំ ការងារ របស់តុលាការ និងអយ្យការ ។

២.៣.២ ផ្តល់លទ្ធភាពដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងបុគ្គលិកចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ។

២.៣.៣ រៀបចំបែងចែក បណ្តុះបណ្តាលចៅក្រម ព្រះរាជអាជ្ញាតាមឯកទេស ។

២.៣.៤ ពង្រឹងក្រមសីលធម៌របស់មន្ត្រីតុលាការ ។

**គោលបំណងទី២.៤ : អនុវត្ត ការប្រមូលប្រាក់ពន្ធចូលថវិការដ្ឋ ឱ្យមានប្រសិទ្ធិភាព**

**យុទ្ធសាស្ត្រ**

២.៤.១ ធានា អោយមានមន្ត្រី បុគ្គលិក ដែលមានសមត្ថភាពក្នុងការចុះបញ្ជី ដោយដៃ ឬប្រព័ន្ធបច្ចេក វិទ្យាលើការត្រួតពិនិត្យប្រាក់ពន្ធដែលត្រូវបង់ចូលថវិការរដ្ឋដោយផ្អែកលើក្រមនិតិវិធីរដ្ឋប្បវេណី

២.៤.២ ធានាក្នុងការធ្វើផែនការថវិការចំណូលនិង បង់ប្រាក់ចូលថវិការរដ្ឋ អោយទាន់ពេលវេលា និង មានប្រសិទ្ធិភាព ដោយផ្អែកលើ ការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមក្រម និតិវិធីរដ្ឋប្បវេណី

២.៤.៣ ធានាអោយមានយន្តការ រៀបចំ និងអនុវត្តប្រព័ន្ធថែរក្សា សៀវភៅបញ្ជីចំណូល ចំណាយ និងឯកសារផ្សេងៗ ដែលបានបិទទុក និងរបាយការណ៍ថវិការចំណូលជាក់ស្តែងដែលត្រូវរាយការណ៍

២.៤.៤ ធានាឱ្យមានការគ្រប់គ្រងទ្រព្យទាំងអស់ ដែលត្រូវតុលាការសម្រេច រឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ត្រូវបង់ ចូលថវិការរដ្ឋ ដោយផ្អែកលើក្រមនិតិវិធី និងគោលការណ៍ច្បាប់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សូចនាករតាមដានការអនុវត្តន៍សម្រាប់ទិសដៅទី២

១. ចំនួនមន្ត្រីមានសមត្ថភាព ប្រៀបធៀបនឹងតម្រូវការរបស់តុលាការ

២. រៀបចំដាក់សំណើថវិកាប្រចាំឆ្នាំបានទាន់ពេលវេលា និងមានគុណភាព

៣. រៀបចំ និងអនុវត្តផែនការថែទាំទ្រព្យសម្បត្តិគ្រប់ប្រភេទ និងផែនការផ្លាស់ប្តូរទីតាំង

៤. ចំនួន និងប្រភេទនៃការបណ្តុះបណ្តាលដែលបានអនុវត្តរៀងរាល់ឆ្នាំ

៥. ចំនួនមន្ត្រីដែលចេះប្រើគ្រឿងបរិក្ខាទំនាក់ទំនងទំនើបៗ

៦. .ការធ្វើផែនការ និងការបង់ចំណូលថវិកាប្រចាំឆ្នាំទាន់ពេលវេលា និងបានល្អត្រឹមត្រូវ

៧ .រៀបចំ និងអនុវត្តផែនការថែរក្សាទ្រព្យសម្បត្តិគ្រប់ប្រភេទទាំងអស់ របស់រដ្ឋ

## ទិសដៅទី ៣ : ការគ្រប់គ្រងតុលាការ និងអយ្យការឱ្យមានប្រសិទ្ធភាព

### គោលបំណងទី៣.១: ការទទួល និងការផ្តល់ព័ត៌មានឱ្យមានប្រសិទ្ធភាព

### យុទ្ធសាស្ត្រ:

៣.១.១ ឱ្យមានបញ្ជរសំរាប់ទទួលភ្ញៀវ ដែលមកទំនាក់ទំនងសួរព័ត៌មានទាក់ទងនឹងកិច្ចការតុលាការ ។

៣.១.២ ត្រូវឱ្យមានមធ្យោបាយ និងប្រព័ន្ធទំនាក់ទំនងប្រាស្រ័យទាក់ទងគ្នារវាងចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងអាជ្ញាសាលាដែលធានាឱ្យបាននូវការងាយស្រួលក្នុងការទទួល និងផ្តល់ព័ត៌មាន ។

៣.១.៣ ត្រូវបង្កើតកន្លែងបិទប្រកាសសាធារណៈឱ្យបានទូលំទូលាយ ។

### គោលបំណងទី៣.២ : បញ្ជីការរឿងក្តីគ្រប់ប្រភេទ

### យុទ្ធសាស្ត្រ:

៣.២.១ រៀបចំឱ្យមានការចុះបញ្ជីរឿងក្តីដោយដៃ និងដោយប្រពន្ធ័អេឡិចត្រូនិច ។

៣.២.២ បង្កើតសៀវភៅចុះបញ្ជីសំណុំរឿង និងយន្តការត្រួតពិនិត្យតាមដាន ។

៣.២.៣ បណ្តុះបណ្តាលមន្ត្រីឱ្យមានសមត្ថភាពក្នុងកិច្ចការចុះបញ្ជី ។

**គោលបំណងទី៣.៣៖ ការគ្រប់គ្រងដំណើរការរបស់តុលាការ និងអយ្យការឱ្យមានប្រសិទ្ធភាព**

**យុទ្ធសាស្ត្រ៖**

៣.៣.១ ធានាឱ្យមានការប្រជុំដើម្បីដោះស្រាយរាល់បាតុភាពអសកម្មក្នុងការងារតុលាការ និងអយ្យការ ឱ្យមានប្រសិទ្ធភាព។

៣.៣.២ ធានាឱ្យមានមន្ត្រី និងបុគ្គលិកដែលមានសមត្ថភាពក្នុងការគ្រប់គ្រង វិភាគទិន្នន័យ និងចាត់ចែងកិច្ចការតុលាការ និងអយ្យការ។

៣.៣.៣ បង្កើនសមត្ថភាពមន្ត្រី បុគ្គលិកក្នុងកិច្ចការធ្វើផែនការរបស់តុលាការ និងអយ្យការ

៣.៣.៤ ជំរុញឱ្យមានការអនុវត្តន៍យុទ្ធសាស្ត្រកំណែទម្រង់តុលាការ និងអយ្យការឱ្យបានល្អ។

**គោលបំណងទី៣.៤៖ ការតម្កល់ឯកសារឱ្យមានប្រសិទ្ធភាព (សំណុំរឿងនិងឯកសារផ្សេងៗ)**

**យុទ្ធសាស្ត្រ៖**

៣.៤.១ ធានាឱ្យមានយន្តការរៀបចំ និង អនុវត្ត ប្រព័ន្ធថែរក្សាសំណុំរឿង សៀវភៅបញ្ជី និង ឯកសារ ផ្សេងៗ ដែលបានបិទទុកងាយស្រួលក្នុងការស្វែងរក។

៣.៤.២ ធានាឱ្យមានកន្លែងសមស្របប្រកបដោយសុវត្ថិភាព សម្រាប់តម្កល់ និងគ្រប់គ្រងឯកសារ។

៣.៤.៣ ធានាឱ្យមានមន្ត្រី បុគ្គលិក ដែលមានសមត្ថភាពក្នុងការគ្រប់គ្រងរៀបចំ និងរក្សាទុកឯកសារ។

៣.៤.៤ ធានាឱ្យមានការគោរពនីតិវិធីក្នុងការតម្កល់ឯកសារ ។

**គោលបំណងទី៣.៥៖ លេខាធិការដ្ឋានដែលបំពេញមុខងារបានល្អ**

**យុទ្ធសាស្ត្រ៖**

៣.៥.១ បង្កើតលេខាធិការដ្ឋានសម្រាប់តុលាការ និង អយ្យការ។

៣.៥.២ បង្កើតប្រតិទិនគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពឱ្យបានទាន់ពេលវេលា ។

៣.៥.៣ ធ្វើគោលនយោបាយ និងការគ្រប់គ្រងទូទៅ ដោយអនុវត្តតាមប្រតិទិនគ្រប់គ្រងផែនការសកម្មភាពការងារ ។

៣.៥.៤ ជំរុញឱ្យមានការធ្វើយុទ្ធសាស្ត្រនិង ផែនការកម្មវិធី ព្រមទាំង ផែនការដទៃទៀត ឱ្យស្របតាមមគ្គុទេសក៍ នៃការធ្វើផែនការក្នុងវិស័យយុត្តធម៌ ។

៣.៥.៥ រៀបចំនីតិវិធីចំណាយហិរញ្ញវត្ថុ។

## សូចនាករតាមដានការអនុវត្តន៍សម្រាប់ទិសដៅទី៣

១. បង្កើត និងដាក់ឱ្យដំណើរការនូវកន្លែងទទួល និងផ្តល់ពត៌មាន

២. បង្កើត និងប្រើប្រាស់ជាប្រចាំនូវប្រព័ន្ធតាមដានសំណុំរឿង

៣. រៀបចំបង្កើត និងធ្វើបច្ចុប្បន្នភាពប្រតិទិនគ្រប់គ្រង

៤. របាយការណ៍របស់តុលាការ/អយ្យការស្របតាមតម្រូវការរបស់ក្រសួងយុត្តិធម៌

៥. ប្រព័ន្ធគ្រប់គ្រងសំណុំរឿង និងវត្ថុតាង ត្រូវបានបង្កើត និងរក្សា

៦. ប្រព័ន្ធតំកល់ឯកសារត្រូវបានបង្កើត និងរក្សា